ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖ ៧៣១
ចុះថ្ងៃទី០២-១២-២០០៩
សាលដីកា
លេខ ៖ ២៤(ប)
ចុះថ្ងៃទី០៣-១២-២០១០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី០៣-១២-២០១០ ដោយមានសមាសភាពដូចខាងក្រោម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

- លោក [redacted]

## ក្រឡាបញ្ជីសវនាការ

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៧៣១ ចុះថ្ងៃទី ០២-១២-២០០៩ ដែលមាន ៖

១- ជនជាប់ចោទឈ្មោះ [redacted] ឈុន ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្រែចាម ឃុំស្រែចាម ស្រុកព្រៃនប់ ខេត្តកំពត ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុន គ្មាន ។



២៦៥

Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] ចាប ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ក្រុងព្រះសីហនុ ទីលំសព្វថ្ងៃក្រុម [redacted] ។

៣-ជនជាប់ចោទឈ្មោះ [redacted] ម៉ាច់ ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] ។

ត្រូវចោទពីបទ ៖ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិស្រែចាម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៥-០៩-២០០៨។ បទល្មើសដែលមានចែង អោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted] ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨-០៩-២០០៩ របស់ឈ្មោះ [redacted] ឈុន សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី ២៨-០៨-២០០៩ គ្រប់សេចក្តីសម្រេចទាំងមូល ។

**<u>ឯរឿងហេតុមានដូចតទៅះ</u>**

កាលពីថ្ងៃទី១៥-៩-២០០៨ វេលាម៉ោង ១៩:០០នាទី ឈ្មោះ [redacted] ឡឿន , [redacted] ធន , [redacted] ចាន់ បានអង្គុយផឹកស្រានៅតូបរបស់ឈ្មោះ [redacted] ឆាន ស្រាប់តែឃើញ [redacted] ឈុន , [redacted] ចាប , [redacted] ម៉ាច់ ជិះម៉ូតូមកឈប់នៅមុខតូប ហើយនិយាយទៅ ស្រីខ័ត ថា អេស្រីស្អាតរួចក៏ជិះម៉ូតូទៅបាត់ ។ មួយសន្ទុះក្រោយមកក៏ត្រឡប់មកវិញ ហើយឈ្មោះ [redacted] ឈុន និយាយថាពួកអាបោកទាបអង្គុយផឹកអីកន្លែងហ្នឹង ពេលនោះឈ្មោះ [redacted] ធនបានស្តីឲ្យឈ្មោះ [redacted] ចាប ថាកុំដើរជាមួយឈ្មោះ [redacted] ឈុន វាជាជើងកាងទេ ហើយក៏ទះកំផ្លៀងមួយដៃក្នុងពេលនោះស្រាប់តែឈ្មោះ [redacted] ឈុន និងឈ្មោះ [redacted] ម៉ាច់ ស្ទុះមកវាយឈ្មោះ [redacted] ធន ឃើញដូច្នេះឈ្មោះ [redacted] ឡឿន ក៏ចូលទៅឃាត់ ។ ក្រោយមកក៏បែកគ្នាមួយសន្ទុះទើបឃើញឈ្មោះ [redacted] ឈុន កាន់ខ្សែក្រវ៉ាត់ ឈ្មោះ [redacted] ចាប និងឈ្មោះ [redacted] ម៉ាច់ កាន់ដំបងចូលមកវាយឈ្មោះ [redacted] ឡឿន បណ្តាលឲ្យដួលសន្លប់នៅនឹងកន្លែង ។

**-បានឃើញសេចក្តីសំរេចរបស់សាលាដំបូងព្រះសីហនុ សម្រេចតាមអំណាចសាលក្រមលេខ ៣៧ "គ" ចុះថ្ងៃទី២៨-០៨-២០០៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១- ផ្តន្ទាទោស ៖

ក-ឈ្មោះ [redacted] ឈុន ភេទប្រុស អាយុ៣៩ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្រែចាម ឃុំស្រែចាម ស្រុកព្រៃនប់ ខេត្តកំពត ទីលំនៅសព្វថ្ងៃក្រុម៥ ភូមិស្រែចាមក្រោម ឃុំអូរជ្រៅ ស្រុក



៧៧០

Scanned with CamScanner

ព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] សារ៉ែន មានកូន ០១នាក់ ទោសពីមុន គ្មាន ។

ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ខែ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ពីបទៈ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែចាម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៥-០៩-២០០៨។ បទល្មើសដែលមានចែង អោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ-ឈ្មោះ [redacted] **ចាប** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ក្រុងព្រះសីហនុ ទីលំសព្វថ្ងៃក្រុម [redacted] ។

គ-ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃក្រុម៥ [redacted] ។

ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ខែ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទៈ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែចាម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពី ថ្ងៃទី១៥-០៩-២០០៨។ បទល្មើសដែលមានចែង អោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **ឈុន**, [redacted] **ចាប** និងឈ្មោះ [redacted] **ម៉ាប់** រួមគ្នាសងសំណងជម្ងឺចិត្តទៅជនរងគ្រោះឈ្មោះ [redacted] **ឡើន** ជាសាច់ប្រាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ [redacted] **ឈុន** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ចាប** និងឈ្មោះ [redacted] **ម៉ាប់** ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨-០៩-២០០៩ របស់ឈ្មោះ [redacted] **ឈុន** សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី ២៨-០៨-២០០៩ គ្រប់សេចក្តីសម្រេចទាំងមូល ។

**បានឃើញ** របាយការណ៍រឿង ចុះថ្ងៃទី០៨-០៦-២០១០ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១៥-៩-២០១០ របស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។



Scanned with CamScanner

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿងហេតុ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធឿន បានឆ្លើយថា : ពួកគេមានគ្នាច្រើន មកដល់វ៉ៃខ្ញុំតែម្ដងខ្ញុំសន្លប់សូមអោយផ្ដន្ទាទោសតាមច្បាប់សុំថ្លៃសំណងដូចថ្នាក់ក្រោម ។

-ឈ្មោះ [redacted] ខន ជាម្ដាយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាប បានឆ្លើយថា : កូនខ្ញុំឈ្មោះ [redacted] ចាប ទៅថៃហើយសព្វថ្ងៃនេះ ។

**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាយ្យការ :**

សំអាងហេតុមានគ្រប់គ្រាន់ហើយសូមតម្កល់សាលក្រម ។

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាយ្យការ

-ក្រោយពីបានពិនិត្យភស្ដុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា</u>**

១-បណ្ដឹងឧទ្ធរណ៍លេខ ៦៥ ចុះថ្ងៃទី០៨-០៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី២៨-៨-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-មានភស្ដុតាងជាចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈុន បានឆ្លើយថា ខ្លួនពិតជាយកខ្សែក្រវ៉ាត់វាយទៅលើឈ្មោះ ធឿន ពិតមែន ។ តាមចម្លើយសាក្សី និងដើមបណ្ដឹងមានភាពស៊ីសង្វាក់គ្នា ដែលបញ្ជាក់ថាឈ្មោះ [redacted] ឈុន ពិតជាបានវាយទៅលើឈ្មោះ [redacted] ធឿន ពិតមែន ។

៣-តំណាងមហាយ្យការបានសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ហើយសុំឲ្យសភាព្រហ្មទណ្ឌសម្រេចតម្កល់សាលក្រមដើម ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី២៨-៨-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចសេចក្ដីត្រឹមត្រូវហើយ សាលាឧទ្ធរណ៍មិនសរសេរសំអាងហេតុនេះដដែលទៀតនោះទេ គប្បីតម្កល់សាលក្រមនេះទុកជាបានការ ។

**<u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី</u>**

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៦៥ ចុះថ្ងៃទី០៨-៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី២៨-៨-២០០៩ របស់





Scanned with CamScanner

សាលាដំបូងខេត្តព្រះសីហនុ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧ "គ" ចុះថ្ងៃទី ២៨-០៨-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៣-១២-២០១០ កំបាំងមុខជនជាប់ចោទ និងចំពោះដើមបណ្តឹងរដ្ឋប្បវេណី បើកឲ្យសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

<u>សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។</u>

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញថ្ងៃទី 07 ខែ 3 ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]